**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់រថយន្តដែលបិទ ឬ បាំងកញ្ចក់

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.**

អនុក្រឹត្យនេះ មានគោលដៅកំណត់ អំពីការបិទបន្ទះផ្លាស្ទិកពណ៌ ឬ ការដាក់របាំង វាំងននបន្ថែមលើកញ្ចក់រថយន្តគ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.**

គោលបំណង នៃអនុក្រឹត្យនេះ ដើម្បី :

- បង្ការ ទប់ស្កាត់បទល្មើសដែលបង្កឡើង ដោយជនល្មើសប្រើប្រាស់រថយន្តបិទកញ្ចក់ពណ៌ ឬ ដាក់របាំង វាំងនន ដែលមើលពីក្រៅទៅក្នុងមិនឃើញ ដើម្បីថែរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- បង្កលក្ខណៈងាយស្រួលដល់ស្ថាប័ន និងមន្ត្រីមានសមត្ថកិច្ចក្នុងការបំពេញភារកិច្ចត្រួតពិនិត្យ ។

មាត្រា ៣.

វិសាលភាព នៃអនុក្រឹត្យនេះគ្របដណ្តប់លើរថយន្តគ្រប់ប្រភេទ ដែលធ្វើចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៤.

វាក្យសព្ទ ក្នុងអនុក្រឹត្យនេះ មានន័យដូចខាងក្រោម :

- កញ្ចក់រថយន្ត សំដៅដល់កញ្ចក់មុខ កញ្ចក់ចំហៀង និងកញ្ចក់ក្រោយ នៃរថយន្ត។
- កញ្ចក់ពណ៌ សំដៅដល់កញ្ចក់រថយន្តដែលផលិតចេញពីរោងចក្រមានពណ៌ស្រអាប់ ឬងងឹតមើលពីក្រៅទៅក្នុងមិនឃើញ។
- កញ្ចក់បិទពណ៌ សំដៅដល់ការយកបន្ទះផ្លាស្ទិកពណ៌ មកបិទលើកញ្ចក់រថយន្ត ដើម្បីប្តូរពណ៌ ឬ ធ្វើឲ្យស្រអាប់ ឬ ងងឹត មើលពីក្រៅចូលទៅក្នុងមិនឃើញ គិតទាំងការដាក់របាំង វាំងនន បាំងកញ្ចក់ គ្រប់ប្រភេទ។

មាត្រា ៥.

ហាមបិទបន្ទះផ្លាស្ទិកពណ៌ ដែលនាំឲ្យមើលពីក្រៅទៅក្នុងរថយន្តមិនឃើញ លើកញ្ចក់រថយន្តដែលធ្វើចរាចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

ហាមនាំចូលនិងធ្វើចរាចរណ៍ចំពោះរថយន្តគ្រប់ប្រភេទមានកញ្ចក់ពណ៌ដែលនាំឲ្យមើលពីក្រៅទៅក្នុងរថយន្តមិនឃើញ ក្នុងព្រះរាជណាចក្រកម្ពុជា លើកលែងតែរថយន្តដែលនាំចូលមុនអនុក្រឹត្យនេះ ។

ចំពោះរថយន្តដែលមានកញ្ចក់បិទពណ៌ស្រអាប់ ឬ ងងឹតមើលពីក្រៅទៅក្នុងមិនឃើញ ត្រូវបកចេញបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។

ការនាំចូលថ្មី នូវរថយន្តកញ្ចក់ពណ៌ ដែលមើលពីក្រៅទៅក្នុងមិនឃើញ ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

មាត្រា ៦.

ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ របាំង វាំងនន សម្រាប់បាំងការពារកំដៅថ្ងៃចាំងចូលរថយន្ត ប៉ុន្តែត្រូវបក ឬ បើកចេញវិញនៅពេលដែលគ្មានកំដៅថ្ងៃចាំងចូល។

ក្នុងពេលតែមួយមិនអនុញ្ញាតឲ្យដាក់របាំង វាំងនន បាំងកញ្ចក់ទាំងសងខាង នៃរថយន្តឡើយ។

មាត្រា ៧.

- ជនណាប្រើប្រាស់រថយន្តកញ្ចក់ពណ៌ ឬ ដាក់របាំង វាំងននបាំងកញ្ចក់ដែលមើលពីក្រៅទៅក្នុងមិនឃើញ ធ្វើចរាចរណ៍លើផ្លូវសាធារណៈ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន)រៀល ហើយត្រូវធ្វើការកែតម្រូវស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។ ក្នុងករណីមិនបានបង់ប្រាក់ពិន័យភ្លាមត្រូវពិន័យបន្ថែម ចំនួន ១០.០០០(មួយម៉ឺន)រៀល ក្នុងមួយថ្ងៃលើប្រាក់ពិន័យមូលដ្ឋាន។

ក្នុងករណីមិនបង់ប្រាក់ពិន័យលើសពី៣០(សាមសិប)ថ្ងៃ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

- ជនណានាំចូលរថយន្តកញ្ចក់ពណ៌ ដែលមើលពីក្រៅទៅក្នុងមិនឃើញ ផ្ទុយនឹងបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ ត្រូវពិន័យអន្តការណ៍ជាប្រាក់ចំនួន២.០០០.០០០ (ពីរលាន)រៀល ហើយត្រូវធ្វើការកែតម្រូវស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ។ ក្នុងករណីមិនបានបង់ប្រាក់ពិន័យភ្លាម ត្រូវពិន័យបន្ថែមចំនួន២០.០០០(ពីរម៉ឺន)រៀលក្នុងមួយថ្ងៃលើប្រាក់ពិន័យមូលដ្ឋាន។

ក្នុងករណីមិនបង់ប្រាក់ពិន័យលើសពី៣០ (សាមសិប)ថ្ងៃ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៨.**

បែបបទនៃការបង់ប្រាក់ពិន័យការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យនិងការចាត់ចែងប្រាក់ចំណូលបានមកពីការពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៩.**

ការផាកពិន័យចំពោះរថយន្តកញ្ចក់ពណ៌ ឬ ដាក់របាំង វាំងននបាំង កញ្ចក់ដែលមើលពីក្រៅទៅក្នុងមិនឃើញ ជាសមត្ថកិច្ចរបស់នគរបាលចរាចរណ៍ផ្លូវគោកនៅតាមគោលដៅត្រួតពិនិត្យ ឬ នៅតាមការិយាល័យនគរបាលចរាចរណ៍ នៃស្នងការដ្ឋាននគរបាល រាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ។

**មាត្រា ១០.**

ក្រសួងមហាផ្ទៃ មានភារកិច្ចចាត់វិធានការ សហការជាមួយអាជ្ញាធរសមត្ថកិច្ច លុបបំបាត់រាល់អំពើដែលប្រព្រឹត្តផ្ទុយទៅនឹងមាត្រា ៥ និងមាត្រា ៦ នៃអនុក្រឹត្យនេះ ។

**មាត្រា ១១.**

មន្ត្រីមានសមត្ថកិច្ចណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ ជាធរមាន។

**មាត្រា ១២.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៣.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ .ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*បានយកសេចក្តីជម្រាបជូន*
*សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*ដើម្បីសូមចុះហត្ថលេខា*
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ